ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៨ សហវ.អគ.ពដ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការត្រួតពិនិត្យការបិទតែមប្រើអាករសំរាប់បញ្ជាក់ការបង់ប្រាក់អាករពិសេសលើទំនិញ និង សេវាមួយចំនួនសំរាប់បារី

កន្លងមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៥១៥ សហវ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការប្រើប្រាស់តែមប្រើអាករសំរាប់បញ្ជាក់ការបង់ប្រាក់អាករពិសេសលើទំនិញ និង សេវាមួយចំនួនសំរាប់បារី, ប្រកាសលេខ ៥៣៩ សហវ.ពដ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០១ ស្តីពីតំលៃ និង លក្ខណៈសំគាល់តែមប្រើអាករសំរាប់បញ្ជាក់ការបង់ប្រាក់អាករពិសេសលើទំនិញ និង សេវាមួយចំនួនសំរាប់បារី, សេចក្តីជូនដំណឹងលេខ ០១៨ សហវ.ពដ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០១ ស្តីពីការដាក់អនុវត្តការប្រើប្រាស់តែមប្រើអាករសំរាប់បញ្ជាក់ការបង់ប្រាក់អាករពិសេសលើទំនិញ និង សេវាមួយចំនួនសំរាប់បារី និង ប្រកាសលេខ ៨៤៣ សហវ.ពដ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការកែប្រែប្រកាសស្តីពីការប្រើប្រាស់តែមប្រើអាករសំរាប់បញ្ជាក់ការបង់ប្រាក់អាករពិសេសលើទំនិញ និងសេវាមួយចំនួនសំរាប់បារី ប្រកាសស្តីពីតំលៃ និង លក្ខណៈសំគាល់តែមប្រើអាករសំរាប់បញ្ជាក់ការបង់ប្រាក់អាករពិសេសលើទំនិញ និង សេវាមួយចំនួនសំរាប់បារី ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យឃើញថា មានក្រុមហ៊ុនបារីមួយចំនួនបានអនុវត្តត្រឹមត្រូវការបិទតែមប្រើអាករ ។ ប៉ុន្តែមានក្រុមហ៊ុនបារីជាច្រើនទៀត ទាំងក្រុមហ៊ុនបារីនាំចូល ទាំងក្រុមហ៊ុនផលិតបារីក្នុងប្រទេស មិនបានអនុវត្តការបិទតែមប្រើអាករ ឬអនុវត្តមិនបានត្រឹមត្រូវការបិទតែមប្រើអាករនេះឡើយ ហើយបានដាក់កញ្ចប់បារី ដែលជាផលិតផលរបស់ខ្លួនធ្វើចរាចរនៅក្នុងទីផ្សារលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនអើពើដល់ការកំណត់នៃលិខិតបទដ្ឋានខាងលើ ។

ដើម្បីអនុវត្តលិខិតបទដ្ឋានខាងលើឱ្យមានប្រសិទ្ធភាព ធានានូវគុណភាពបារី ជៀសវាងនូវការក្លែងបន្លំម៉ាកបារី ធានាបាននូវការទុកចិត្តរបស់អ្នកប្រើប្រាស់ ធានានូវការប្រកួតប្រជែងឱ្យមានភាពស្មើគ្នារវាងក្រុមហ៊ុនបារី ជៀសវាងនូវការគេចវេសពន្ធអាករក្នុងពេលនាំចូល ក៏ដូចជាពេលបញ្ចេញផលិតផលពីរោងចក្រក្នុងស្រុក និង បង្កើនចំណូលជូនរដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជំរាបជូនដំណឹងដល់ក្រុមហ៊ុនផលិតបារីក្នុងប្រទេស និងក្រុមហ៊ុននាំចូលបារីទាំងអស់ ត្រូវអនុវត្តការបិទតែមប្រើអាករដូចមានចែងក្នុងប្រកាសលេខ ៥១៥ សហវ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០១ ឱ្យបានត្រឹមត្រូវ ហើយចាប់ពីថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០០២ តទៅ អាជ្ញាធរមានសមត្ថកិច្ចនឹងចុះធ្វើការត្រួតពិនិត្យការបិទតែមប្រើអាករនៅតាមរោងចក្រ សហគ្រាស កន្លែងផលិត ឃ្លាំងស្តុកសំរាប់ទីផ្សារក្នុងស្រុកនៃព្រះរាជាណាចក្រកម្ពុជា កន្លែងលក់បារីនៅក្នុងទីផ្សារលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬមធ្យោបាយដឹកជញ្ជូនបារីសំរាប់ទីផ្សារ

ក្នុងស្រុកនៃព្រះរាជាណាចក្រកម្ពុជា និង ការត្រួតពិនិត្យផ្សេងទៀត តាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ និង បទប្បញ្ញត្តិស្តីពីគយនិងរដ្ឋាករ ។

ក្នុងពេលចុះធ្វើការត្រួតពិនិត្យ បើមានករណីរកឃើញបារីដែលមិនមានបិទតែមប្រើអាករ ឬបារីបិទតែមប្រើអាករក្លែងក្លាយ ឬបិទតែមប្រើ អាករដែលបានប្រើប្រាស់រួចហើយ ឬបិទតែមប្រើអាករមិនត្រឹមត្រូវតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាជ្ញាធរមានសមត្ថកិច្ចនឹងធ្វើការឃាត់ទុក និងឃុំគ្រងបារីទាំងនោះ ហើយតំរូវអោយម្ចាស់បារីដែលរួមមាន អ្នកនាំចូលបារី រោងចក្រផលិតបារី ម្ចាស់ឃ្លាំងស្តុកទុកបារីសំរាប់ទីផ្សារក្នុងស្រុក អ្នកលក់បារី មកទិញបារីវិញក្នុងតម្លៃស្មើនឹងថ្លៃលក់នៅលើទីផ្សារក្នុងស្រុកនៅពេលរកឃើញ ឬដាក់លក់ដោយវិធីដេញថ្លៃ ឬបំផ្លាញចោល ។ ក្រៅពីនោះ ចំពោះ :

១- បារីដែលមិនមានបិទតែមប្រើអាករ អ្នកនាំចូលបារី រោងចក្រផលិតបារី ម្ចាស់ឃ្លាំងស្តុកទុកបារីសំរាប់ទីផ្សារក្នុងស្រុក អ្នកលក់បារី ត្រូវទទួលរងនូវទោសទណ្ឌពីបទគេចវេសពន្ធ ដូចមានចែងក្នុងប្រការ ១៤ ប្រកាស លេខ ៥១៥ សហវ មាត្រា ១២៧ និង មាត្រា ១៣៥ នៃច្បាប់ស្តីពីសារពើពន្ធ ។

២ បារីបិទតែមប្រើអាករក្លែងក្លាយ ឬបិទតែមប្រើអាករដែលបានប្រើប្រាស់រួចហើយ ឬបិទតែមប្រើអាករមិនត្រឹមត្រូវតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អ្នកនាំចូលបារី រោងចក្រផលិតបារី ម្ចាស់ឃ្លាំងស្តុកទុកបារីសំរាប់ទីផ្សារក្នុងស្រុក អ្នកលក់បារី ត្រូវទទួលរងនូវទោសទណ្ឌពីបទអំពើរាំងស្ទះ ដូចមានចែងក្នុងប្រការ ១៥ ប្រកាសលេខ ៥១៥ សហវ មាត្រា ១២៨ មាត្រា ១៣៣ និង មាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រី ជាប្រធានសហគ្រាស ក្រុមហ៊ុនផលិតបារីក្នុងស្រុក អ្នកនាំចូលបារី ឬអ្នកលក់មកក្នុងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាប និង អនុវត្តការបិទតែមប្រើអាករឱ្យបានត្រឹមត្រូវតាមការតំរូវនៃបទប្បញ្ញត្តិស្តីពីការបិទតែមប្រើអាករនេះ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**<u>កន្លែងទទួល:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង- ស្ថាប័នកណ្តាល
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ- ទីចាត់ការគយ និងរដ្ឋាករ
  " ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ